# ប្រវត្តិសង្ខេប

១- ខ្ញុំរៀនកំណាព្យ ឆ្នាំហុកប្រាំបី កាលនៅយុវវ័យ អាយុដប់ប្រាំ
ក្រោយបងលាវ-គាន ជួយបណ្តុះផ្សាំ ឲ្យបានចេះចាំ ដឹងក្បួនតម្រា ។

២- ហេតុតែស្រឡាញ់ ងប់នឹងកំណាព្យ ទើបរៀនបានឆាប់ ដឹងគ្រប់ប្រការ
ឆ្នាំចិតសិបបី ទទួលតុក្កតា រង្វាន់ប្រើជា ឥន្ទបាត់ដំបង ។

៣- កំណាព្យបង្ហាញ ឲ្យន័យច្រើនបែប ទោះបទសង្ខេប ន័យច្រើនកន្លង
ស្រួលចេះងាយចាំ ឆាប់រត់មាត់ផង អាចចងចម្រៀង ច្រៀងសញ្ញេតនា ។

៤- អក្សរសាស្ត្រចម្រើន កើនប្រពៃណី បុរសនារី គួររៀនកាព្យា
បើមិនចេះក្បួន ខ្ញុំនឹងពណ៌នា បង្រៀនគ្រប់គ្នា ឲ្យចេះជាក់ស្តែង ។

៥- ខ្ញុំមានក្បួនគ្រប់ ក្បួនថ្មីក្បួនចាស់ ក្បួនខ្លះខ្ញុំឃើញ គំហើញខ្លួនឯង
ខ្ញុំបានចងក្រង ក្បួនមួយយ៉ាងវែង ហើយតែងសៀវភៅ ច្រើនរយសន្លឹក ។

៦- លោកអ្នកនៅឆ្ងាយ ប្រើអ៊ិន្ធឺណិត ឯអ្នកនៅជិត ខ្ញុំនឹងបង្ហឹក
ឲ្យចេះក្បួនច្បាប់ កំណាព្យយ៉ាងថ្មឹក ចង់សិក្សទាក់ទង ដោយក្តីមេត្រី ។

៧- ចងក្រងឯកសារ ស្នាដៃនិពន្ធ មានគ្រាន់បង្គួរ ស្នាដៃម្ភៃបី
ទុកជូនបងប្អូន សន្តានប្រុសស្រី អាក្រក់ល្អក្តី ចេះតែខំឆ្លៀត ។

៨- ច្រៀង១២បទ បានថតស៊ីឌី ខ្ញុំនឹងសម្តី ឲ្យគេច្រៀងទៀត
ឯការសិក្សា នៅតែខំឆ្លៀត បន្តទៅទៀត ឲ្យបានឯកទេស ។

៩- គឺផ្នែក Business Administration តែប៉ិនខាងខ្មែរ ជាងឯបរទេស
ធ្វើម្តេចកើតខ្មែរ ឈាមខ្មែរជាតិនេះ ត្រូវរិះជួយខ្មែរ តាមការតម្រូវ ។

១០- បើទោះជាស្លាប់ ហើយកើតជាតិក្រោយ សូមឲ្យកើតខ្មែរ ជាតរៀងទៅ
តែបច្ចុប្បន្ន យើងត្រូវរកផ្លូវ ជួយខ្មែរឥឡូវ សាមគ្គីសប្បាយ ។

១១- លោកភេម-សុខុន នូវវែលហេរឡង់ លោកពូកែខ្វង់ ខាងធ្វើវិបសាយ
យកកំណាព្យខ្ញុំ ទៅដាក់ចុះផ្សាយ ជូនញាតិទាំងឡាយ អានទាំងប្រុសស្រី។

១២- ការផ្សាយចាប់ផ្ដើម ថ្ងៃ១មេសា ឆ្នាំថ្មីនេះណា គឺ២០០៣
អានហើយសូមជួយ ទិទៀនកវី ដើម្បីរូបខ្ញុំ ខំកែឲ្យល្អ ។
១៣- ឆ្នាំ២០០៣ ថ្ងៃ៧មេសា មួង-មុនីរដ្ឋា ក៏បានអបអរ
យកកំណាព្យខ្ញុំ ជួយផ្សាយបន្ត ព្រោះគាត់បានក វិបមួយស្រឡាង។
១៤- ខ្ញុំសែនរីករាយ នឹងលោកទាំងអស់ ដែលខំដោយស្មោះ ត្រួយត្រាយកសាង
ខំធ្វើវិបសាយ ដូចមានភស្តុតាង សំអាងដាក់ជូន នូវគ្រប់ទង្វើ ។
១៥- www.sokhon-phem.com លោកបានរៀបចំ តាមវគ្គមានស្នើ
ទុកជូនបងប្អូន គ្រាន់នឹងចូលមើល៍ សូមធ្វើទិទៀន ជួយពិភក្សា ។
១៦- ង www.khmervoice.com រៀបចំដោយក្រុម មួង-មុនីរដ្ឋា
ប៊ុនកាសេម-ថាវរិទ្ធិ រួមសហការ លោកហាយ៉ាតូ-អៀរីយ៉ូមី ។
១៧- សូមជួយគាំទ្រ រួចសូមជួយផ្ដល់ យោបល់នេះហើយ ជាតួសាមគ្គី
ចំណែកយើងខ្ញុំ ធ្វើតាមនាទី ឲ្យស៊ីចង្វាក់ នឹងបានដល់ត្រើយ ។
១៨- សូមអស់លោកអ្នក មានស្រីស្តី កវីសូមលា មួយគ្រាសិនហើយ
សូមអានកំណាព្យ រួចជាសះស្បើយ អារម្មណ៍ហើយ ពីក្ដីទុក្ខា ។

ថ្ងៃទី១៩មីនាឆ្នាំ២០០៣
គឹម-ច័ន្ទវង្ស
chanvongkim@yahoo.com
អ្នកនិពន្ធទទួលរង្វាន់ជំនាន់
សុតន្ត ប្រីជាឥន្ទ, បាត់ដំបង ឆ្នាំ១៩៧៣